CITY OF LONG BEACH PUBLIC NOTICE

សេចក្តីជូនដំណឹងសាធារណៈ ថ្ងៃទី ១៣ ខែឧសភាឆ្នាំ២០២០

# ច្បាប់សម្រាប់ការបោសថ្នល់នឹងបន្តអនុវត្តន៍នៅថ្ងៃច័ន្ទទី ១៨ ខែឧសភា

បន្ទាប់ពីការលើកលែងទោសរយៈពេល ៩ សប្តាហ៍ចំពោះការចតរថយន្តពេលបោសថ្នល់ទីក្រុងឡុងប៊ិច នឹងចាប់ផ្តើមអនុវត្តច្បាប់ចតឡើងវិញដែលពាក់ព័ន្ធនឹងការបោសថ្នល់នៅថ្ងៃច័ន្ទទី ១៨ ខែឧសភា។

ក្នុងរយៈពេលពីរខែកន្លងមកនេះប្រតិបត្តិការនានាបានបន្តនៅក្នុងតំបន់ដែលម៉ាស៊ីនបោសថ្នល់អាចចូលបោសសំអាតបានដែលប្រកបដោយប្រសិទ្ធភាព។ ប៉ុន្តែនៅតាមសង្កាត់ជាច្រើនការស្ទះតាមដងផ្លូវបាននាំឱ្យមានការប្រមូលផ្តុំនូវដីល្បាប់និងកំទេចកំទីដែលជាផលលំបាកដល់សមត្ថភាពរបស់ទីក្រុងក្នុងការបំពេញតាមស្តង់ដារជាតិក្នុងការរក្សាឱ្យផ្លូវទឹកស្អាត។

ការបោសសំអាតតាមដងផ្លូវគឺជាសេវាកម្មសុខភាពដ៏សំខាន់មួយដែលប្រមូលកំទេចកំទីរាប់ពាន់តោនជារៀងរាល់ឆ្នាំនិងលុបបំបាត់ការបំពុលមិនឱ្យហូរទៅក្នុងសមុទ្រឬទន្លេ។ ការបោសថ្នល់អាចអនុវត្តដោយប្រសិទ្ធិភាពនៅពេលដែលរថយន្តនៅឆ្ងាយពីផ្លូវអ្នកបោសតែប៉ុណ្ណោះ។

ចាប់តាំងពីថ្ងៃទី ៤ ខែឧសភាបុគ្គលិកនៃមន្ទីរសាធារណការបានដាក់ការរំលឹកជាភាសាអង់គ្លេស អេស្ប៉ាញ ខ្មែរ និងតាហ្គាល លើរថយន្តដែលមិនបានផ្លាស់ប្តូរកន្លែងចតនៅក្នុងម៉ោងបោសថ្នល់។ ការរំលឹកនេះបានណែនាំដល់ប្រជាជនអំពីធនធានសម្រាប់ការចតរថយន្តដែលមាននៅទូទាំងទីក្រុងហើយក៏ជម្រាបប្រជាជនអោយបានដឹងថាការអនុវត្តច្បាប់បោសថ្នល់នឹងចាប់ផ្តើមឡើងវិញនៅថ្ងៃទី ១៨ ខែឧសភា។

ការលើកលែងទោសចំពោះការចតរថយន្តត្រូវបានអនុវត្តដំបូងជាផែនការផ្តល់ជំនួយសេដ្ឋកិច្ចដល់ប្រជាជនក្នុងពេលមានគ្រោះអាសន្នផ្នែកសុខភាពនៃជំងឺកូវីដ-១៩នេះ។ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាចំណតដែលបង្កឡើងដោយជំងឺកូវីដ-១៩ទីក្រុងឡុងប៊ិចបានបង្កើតកន្លែងចតរថ

យន្តចំនួនជាង ៤០០០ កន្លែង។ កន្លែងចតរថយន្តទាំងនេះមានទីតាំងនៅទូទាំងទីក្រុង។ បញ្ជីពេញលេញនៃជម្រើសកន្លែងចតរថយន្តអាចរកបាននៅទីនេះ។ ចំណតរថយន្តសម្រាប់ប្រជាពលរដ្ឋដោយមានលិខិតអនុញ្ញាតនឹងបន្តរហូតដល់មានការជូនដំណឹងបន្ថែម។

ការសាកសួររបស់អ្នកសារព័ត៌មានអាចបញ្ជូនទៅកាន់មជ្ឈមណ្ឌលព័ត៌មានរួមនៅទីក្រុងឡុងប៊ិចនៅលេខ 562.570.NEWS ឬតាមអ៊ីមែលនៅ jic@longbeach.gov។ ប្រជាពលរដ្ឋអាចទូរស័ព្ទមកលេខ 562.570.INFO ប្រសិនបើមានសំណួរ។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័ហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #